# យោបល់ជំទាស់របស់ចៅក្រម Klonowiecka-Milart និងចៅក្រម Jayasinghe

១. យើងឯកភាពជាមួយមតិភាគច្រើនដែលថា បណ្តឹងសាទុក្ខនេះពុំស្របទៅនឹងភាសាសាមញ្ញនៃវិធាន ១០៤ ឡើយ។ លើសពីនេះទៀត យើងក៏ឯកភាពថា ពុំមានសិទ្ធិប្តឹងសាទុក្ខភ្លាមៗយ៉ាងដូច្នេះនោះទេ។ ទោះជាបែបនេះក្តី យើងជំទាស់ទៅនឹងអំណះអំណាងមិនច្បាស់លាស់ដែលថា យុត្តាធិការរបស់អង្គជំនុំជម្រះនេះលើបណ្តឹងសាទុក្ខភ្លាមៗត្រូវបានកំហិតតឹងរ៉ឹងត្រឹមកាលៈទេសៈចង្អៀត ដូចមានរៀបរាប់ក្នុងវិធាន ១០៤ (៤)។ សេចក្តីសន្និដ្ឋាននេះពុំស្របជាមួយនឹងយុត្តិសាស្ត្ររបស់ អ.វ.ត.ក ទម្លាប់អនុវត្តន៍របស់តុលាការព្រហ្មទណ្ឌអន្តរជាតិដែលមានស្រាប់ តម្រូវការនៃការជំនុំជម្រះដោយយុត្តិធម៌និងឆាប់រហ័ស និងសិទ្ធិរបស់ជនជាប់ចោទនោះទេ។ ផ្ទុយទៅវិញ យោងតាមមាត្រា ៣៣ ថ្មីនៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក យើងយល់ថា អង្គជំនុំជម្រះតុលាការកំពូលអាចអនុវត្តយុត្តាធិការលើបណ្តឹងសាទុក្ខភ្លាមៗ ដែលពាក់ព័ន្ធនឹងបញ្ហាណាមួយដែលនឹងប៉ះពាល់ជាសារវន្តដល់ការប្រព្រឹត្តិទៅដោយយុត្តិធម៌ និងឆាប់រហ័សនៃកិច្ចដំណើរការនីតិវិធី ឬលទ្ធផលនៃការជំនុំជម្រះ និងដែលដំណោះស្រាយភ្លាមៗរបស់អង្គជំនុំជម្រះតុលាការកំពូលអាចពន្លឿនកិច្ចដំណើរការនីតិវិធីបានយ៉ាងពិតប្រាកដ។ យើងសម្រេចទៀតថា បណ្តឹងសាទុក្ខនាពេលបច្ចុប្បន្នមានលក្ខណៈជាបណ្តឹងសាទុក្ខបែបនេះឯង។

២. កិច្ចដំណើរការនីតិវិធីនៅឯតុលាការឧក្រិដ្ឋកម្មអន្តរជាតិនានា បានបង្ហាញថាមានលក្ខណៈវែងអន្លាយ។ ការជំនុំជម្រះនានានៅឯតុលាការឧក្រិដ្ឋកម្មអន្តរជាតិ ជាទូទៅបានចំណាយពេលជាច្រើនឆ្នាំ ចាប់តាំងពីពេលមានសវនាការលើកស្តុតាង រហូតដល់ពេលមានសាលក្រមជំនុំជម្រះ[1]។ ក្នុងសំណុំរឿង ០០១ នៅ អ.វ.ត.ក កិច្ចដំណើរការនីតិវិធីជំនុំជម្រះបានចំណាយពេលវេលាអស់ចំនួន ៨ ខែ នឹងចំណាយពេលវេលាចំនួន ៩ ខែទៀត មុនពេលនៃការចេញសាលក្រមជំនុំជម្រះ[2]។ ការជំនុំជម្រះក្នុងសំណុំរឿង ០០២ ពាក់ព័ន្ធទៅនឹងជនជាប់ចោទចំនួន៤ នាក់ មិនមែន ១ នាក់នោះទេ ហើយបន្ថែមការចោទប្រកាន់អំពីអំពើប្រល័យពូជសាសន៍

---

[1] Antonio Cassese, "ស្ថិតិស្តីពីការប្រើប្រាស់ប្រកបដោយប្រសិទ្ធភាពនៃបន្ទប់សវនាការ និងផលិតភាពរបស់តុលាការ", ឧបសម្ព័ន្ធ ឃ ភ្ជាប់មកជាមួយនឹង "របាយការណ៍ស្តីពីតុលាការពិសេសសម្រាប់សៀរ៉ាឡេអូន", ថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០០៦, ទំព័រ ៤៩ ដែលមាននៅលើគេហទំព័រ <http://www.sc-sl.org>។

[2] សាលក្រម, សំណុំរឿង 001/18-07-2007/អ.វ.ត.ក/អ.ជ.ស.ដ, ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០, ឯកសារ E188, កថាខណ្ឌ៩។

00813585



និងដែលពាក់ព័ន្ធនឹងវិសាលភាពទូលំទូលាយជាងមុន នៃការចោទប្រកាន់ដោយផ្អែកលើអង្គហេតុ[3]។ ការជំនុំជម្រះក្នុងសំណុំរឿង ០០២ ត្រូវបានគេព្យាករណ៍ថា នឹងចំណាយពេលវេលាយ៉ាងហោចណាស់ចំនួន៤ឆ្នាំទៀត[4]។ បណ្តឹងសាទុក្ខណាមួយដែលពុំអាចត្រូវបានស្តាប់ភ្លាមៗ ជាចាំបាច់នឹងត្រូវពន្យារពេល យ៉ាងឆាប់បំផុតក៏រហូតដល់ឆ្នាំ២០១៤ដែរ[5]។

៣. វិធាន និងទម្លាប់អនុវត្តន៍ពាក់ព័ន្ធនឹងយុត្តាធិការលើបណ្តឹងសាទុក្ខ នៅឯតុលាការឧក្រិដ្ឋកម្មអន្តរជាតិដទៃទៀត ពន្យល់អំពីការពិតជាក់ស្តែងនេះ។ តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី ICTY, តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់រវ៉ាន់ដា ICTR, តុលាការពិសេសសម្រាប់សៀរ៉ាឡេអូន SCSL និងតុលាការព្រហ្មទណ្ឌអន្តរជាតិ ICC ផ្តល់សិទ្ធិប្តឹងសាទុក្ខភ្លាមៗ ចំពោះសេចក្តីសម្រេចណាមួយស្តីពីយុត្តាធិការ និងឱកាសបន្ថែមមួយទៀត ដើម្បីស្នើសុំការអនុញ្ញាតក្នុងការប្តឹងសាទុក្ខ ទាក់ទិននឹងបញ្ហាណាមួយ "ដែលនឹងប៉ះពាល់ជាសារវន្តដល់ការប្រព្រឹត្តិទៅដោយត្រឹមត្រូវនិងឆាប់រហ័ស នៃកិច្ចដំណើរការនីតិវិធី ឬលទ្ធផលនៃការជំនុំជម្រះ"[6]។ តុលាការទាំងនេះរមែងបានផ្តល់ការអនុញ្ញាតក្នុងការប្តឹងសាទុក្ខ ដោយអនុលោមតាមអំណាចឆន្ទានុសិទ្ធិនេះ ក្នុងពេលដែលសាលដីកាលើបណ្តឹងសាទុក្ខ ពាក់ព័ន្ធនឹងបញ្ហាមួយដែល

---

[3] ដីកាដំណោះស្រាយបញ្ជូនជនជាប់ចោទ កាំង ហ្គេកអ៊ាវ ហៅ ឌុច ទៅជំនុំជម្រះ, សំណុំរឿង ០០១/១៨-០៧-២០០៧/អ.វ.ត.ក/អ.ជ.ស.ដ, ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ២០០៨ ឯកសារ D99 ("ដីកាដំណោះស្រាយ សំណុំរឿង ០០១"), កថាខណ្ឌ ១០-១២៨; ដីកាដំណោះស្រាយ, ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០, ឯកសារ D427 ("ដីកាដំណោះស្រាយនៃសំណុំរឿង ០០២"), កថាខណ្ឌ ១៨-១២៩៨។

[4] "កាលវិភាគជំនុំជម្រះរបស់ អ.វ.ត.ក សំណុំរឿង ១ និង ២", ឯកសារឧបសម្ព័ន្ធភ្ជាប់ទៅនឹងថវិកាស្នើសុំរបស់ អ.វ.ត.ក សម្រាប់ឆ្នាំ ២០១២-២០១៣ ដែលមាននៅលើគេហទំព័រ <http://www.cccc.gov.kh/sitcs/dcfault/filcs/Anncx%20A-D.pdf> ("ការព្យាករថវិការបស់ អ.វ.ត.ក")។

[5] ដោយអនុលោមតាមដីកាបំបែកសំណុំរឿងរបស់អង្គជំនុំជម្រះសាលាដំបូង សាលក្រមបឋមនឹងចេញស្តីពីបទចោទប្រកាន់មួយចំនួនតូច ពាក់ព័ន្ធនឹងការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី I និងដំណាក់កាលទី II។ *សូមមើល* ដីកាបំបែកសំណុំរឿង ដោយអនុលោមតាមវិធាន ៨៩*ស្ទួនពីរ* នៃវិធានផ្ទៃក្នុង, ថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១១, ឯកសារ E124។ សវនាការដំណាក់កាលទីមួយនេះត្រូវបានព្យាករថានឹងបញ្ចប់នៅក្នុងខែ មិថុនា ឆ្នាំ ២០១៣ (*សូមមើល* ការព្យាករណ៍ថវិការបស់ អ.វ.ត.ក) ដែលកិច្ចដំណើរការនីតិវិធីលើបណ្តឹងសាទុក្ខនឹងចាប់ផ្តើម។

[6] វិធាននៃនីតិវិធី និងភស្តុតាងរបស់តុលាការ ICTY, វិធាន ៧២(ខ) វិធាន ៧៣(ខ); វិធាននៃនីតិវិធី និងភស្តុតាងរបស់តុលាការ ICTR, វិធាន ៧២(ខ), វិធាន ៧៣(ខ); វិធាននៃនីតិវិធី និងភស្តុតាងរបស់តុលាការ SCSL, វិធាន ៧២ (ង), (ច), វិធាន ៧៣ (ខ); ច្បាប់លក្ខន្តិកៈតុលាការ ICC, មាត្រា ៨២(១)(ឃ)។

សំខាន់សម្រាប់ការជំនុំជម្រះដែលកំពុងប្រព្រឹត្តទៅ រួមទាំងសិទ្ធិអំណាចរបស់អង្គជំនុំជម្រះក្នុងការអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួនទៅលើជនជាប់ចោទ[7]។ ប៉ុន្តែ វិសាលភាពនៃបណ្តឹងសាទុក្ខ ដោយអនុលោមតាមវិធាន ១០៤(៤) នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក ហាក់ដូចជាមានភាពតូចចង្អៀតមិនអាចពន្យល់បាន។ យើងយល់ឃើញថា អង្គជំនុំជម្រះតុលាការកំពូលគួរអនុវត្តតាមទម្លាប់អនុវត្តន៍របស់តុលាការអន្តរជាតិនានា និងទទួលយកបណ្តឹងសាទុក្ខនេះនៅក្នុងការអនុវត្តអំណាចឆន្ទានុសិទ្ធិរបស់ខ្លួន។ ស្រដៀងគ្នានេះ នៅ អ.វ.ត.ក អង្គបុរេជំនុំជម្រះបានប្រកាន់យកការបកស្រាយក្នុងន័យទូលាយ ស្តីពីយុត្តាធិការលើបណ្តឹងសាទុក្ខរបស់ខ្លួននៅក្នុងកាលៈទេសៈ ដែលសិទ្ធិរបស់ជនជាប់ចោទស្ថិតក្រោមហានិភ័យ[8]។

៤. ស្ថានភាពបច្ចុប្បន្នដែលតម្រូវឱ្យមានដំណោះស្រាយភ្លាមៗ លើបណ្តឹងសាទុក្ខនាពេលបច្ចុប្បន្ន មានលក្ខណៈចាប់បង្ខំ ដោយហេតុថា គោលការណ៍ *គ្មានការកាត់សេចក្តី ២ ដង លើបទល្មើសតែមួយ* (*ne bis in idem*)

---

[7] *សំណុំរឿង រដ្ឋអាជ្ញា ទល់នឹង*, លេខសំណុំរឿង IT-94-1-AR72, សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តីស្នើសុំធ្វើបណ្តឹងសាទុក្ខបន្ទាន់បង្ខំស្តីពីយុត្តាធិការ, អង្គជំនុំជម្រះតុលាការឧទ្ធរណ៍, ថ្ងៃទី ២ ខែ តុលា ឆ្នាំ ១៩៩៥, កថាខណ្ឌ ៦, ("បញ្ហាជាសារវន្តដូចជាយុត្តិសាស្ត្រ របស់តុលាការអន្តរជាតិ ពុំគួរត្រូវបានរក្សាសម្រាប់ធ្វើសេចក្តីសម្រេច រហូតដល់ចុងបញ្ចប់នៃការជំនុំជម្រះ ដែលអាចចំណាយថវិកាច្រើន និងចំណាយអស់ពេលវេលាច្រើន និងពុំមានហេតុផលសមស្របនោះទេ")។

[8] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ចំពោះដីកាសម្រេចលើសំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណីសុំបំពេញកិច្ចស៊ើបសួរ ទាក់ទិននឹងទ្រព្យសម្បត្តិទាំងអស់ដែលជនត្រូវចោទមាន, ថ្ងៃទី ៤ ខែ សីហា ឆ្នាំ ២០១០, ឯកសារ D193/5/5, កថាខណ្ឌ ១៩ ("អនុលោមតាមវិធាន ២១ នៃវិធានផ្ទៃក្នុង បណ្តឹងឧទ្ធរណ៍អាចទទួលយកបាន ប្រសិនបើភាគីចោទប្រកាន់ថាមានការរំលោភបំពានលើការអនុវត្តសិទ្ធិដែលត្រូវបានការពារដោយវិធាន ២១ នៃវិធានផ្ទៃក្នុង"); សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងទៅនឹងសេចក្តីសម្រេចរបស់ ក.ស.ច.ស បដិសេធមិនទទួលយកការដាក់ឯកសារចម្លើយតបរបស់លោក អៀង សារី ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៦៦ និងសេចក្តីសង្កេតបន្ថែម និងសំណើសុំផ្អាកដំណើរការនីតិវិធី, ថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០១០, ឯកសារ D390/1/2/4, កថាខណ្ឌ ១៣ ("អង្គបុរេជំនុំជម្រះបានសម្រេចថា វិធាន ២១ នៃវិធានផ្ទៃក្នុងតម្រូវថា អង្គបុរេជំនុំជម្រះត្រូវបកស្រាយឱ្យបានទូលំទូលាយនូវសិទ្ធិរបស់ជនត្រូវចោទក្នុងការប្តឹងឧទ្ធរណ៍ ដើម្បីធានាថា សិទ្ធិរបស់ជនត្រូវចោទក្នុងការទទួលបានការកាត់សេចក្តីដោយយុត្តិធម៌ ត្រូវបានគាំពារក្នុងកាលៈទេសៈនេះ។ ដោយហេតុថា នេះគឺជាបញ្ហាមួយពាក់ព័ន្ធនឹងគោលការណ៍ "ស្មើភាពចំពោះមុខច្បាប់" និង "សមភាពនៃមធ្យោបាយតទល់រឿងក្តី" ដោយគិតអំពីភារកិច្ចរបស់អង្គជំនុំជម្រះ ដូចមានចែងត្រង់វិធាន ២១ នៃវិធានផ្ទៃក្នុង និងកាលៈទេសៈនៃបណ្តឹងឧទ្ធរណ៍នេះ អង្គបុរេជំនុំជម្រះសម្រេចទទួលយកបណ្តឹងឧទ្ធរណ៍នេះ")។ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេត សម្រេចបដិសេធសំណើសុំអនុញ្ញាតថតសំឡេង/រូបភាពវីដេអូ នៃការជួបជាមួយលោក អៀង សារី នៅក្នុងមន្ទីរឃុំឃាំង, ថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០១០, ឯកសារ A371/2/12, កថាខណ្ឌ ១៨។

ហាមឃាត់មិនឱ្យមានការផ្តន្ទាទោសច្រើនផង និងហាមឃាត់មិនឱ្យមានការជំនុំជម្រះច្រើនដងផង[9]។ ពេលវេលា សភាពតានតឹងផ្លូវចិត្ត និង (ទោះបីពុំពាក់ព័ន្ធនៅទីនេះក៏ដោយ) តម្រូវការហិរញ្ញវត្ថុនៃការជំនុំជម្រះ ត្រូវបានគេយល់ជាទូទៅថា ជាការធ្វើឱ្យខូចប្រយោជន៍ជនជាប់ចោទយ៉ាងធ្ងន់ធ្ងរ ទោះបីនៅក្នុងករណីមានការសម្រេចឱ្យជនជាប់ចោទ រួចផុតពីបទចោទក៏ដោយ[10]។ នៅ អ.វ.ត.ក ការខូចប្រយោជន៍នោះមានលក្ខណៈធ្ងន់ធ្ងរ នៅពេលដែលជនជាប់ចោទត្រូវបានឃុំខ្លួននៅមន្ទីរឃុំឃាំងក្នុងអំឡុងពេលនៃការផ្អាកការជំនុំជម្រះ[11]។ ប្រសិនបើអង្គជំនុំជម្រះតុលាការកំពូលសម្រេចដោយថាហេតុណាមួយថា *គោលការណ៍គ្មានការកាត់សេចក្តី ២ ដង លើបទល្មើសតែមួយ* ហាមឃាត់កិច្ចដំណើរការនីតិវិធីដែលកំពុងប្រព្រឹត្តទៅប្រឆាំងនឹងជនជាប់ចោទក្នុងសំណុំរឿង ០០២ គាត់នឹងត្រូវស្ថិតនៅក្រោមការឃុំខ្លួនដែលគ្មានមូលដ្ឋាន និងមិនអាចជៀសផុតចំនួនជាច្រើនឆ្នាំ រួមទាំងការបង្ខិតបង្ខំផ្លូវកាយជាយូរៗម្តងដើម្បីចូលរួមកិច្ចដំណើរការនីតិវិធីរបស់តុលាការ[12]។ ការខូចប្រយោជន៍ដែលអាចកើតមានដល់សិទ្ធិជាសារវ័ន្តក្នុងការទទួលបានសេរីភាព គឺមានទំហំធំធេង ទើបវិធាន២១(១) នៃវិធានផ្ទៃក្នុង មាត្រា ១៤(៣)(គ) នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ និងមាត្រា ៣៣ ថ្មីនៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក បង្គាប់ឱ្យអង្គជំនុំជម្រះតុលាការកំពូលធ្វើការពិនិត្យពិចារណា ឱ្យបានគ្រប់ជ្រុងជ្រោយទៅលើបណ្តឹងសាទុក្ខនេះ នៅដំណាក់កាលដំបូងបំផុតតាមដែលខ្លួនអាចធ្វើទៅបាន។

៥. ជាចុងក្រោយ យើងកត់សម្គាល់ឃើញថា ការទទួលយកបណ្តឹងសាទុក្ខនៅដំណាក់កាលនេះ ជាទូទៅពុំមានផលប៉ះពាល់អវិជ្ជមានណាមួយមកលើការជំនុំជម្រះលើសំណុំរឿង ០០២ ឬកិច្ចដំណើរការនីតិវិធីនៅចំពោះមុខ អ.វ.ត.ក ឡើយ។ នៅទីបំផុត បញ្ហាទាំងប៉ុន្មានដែលបានលើកក្នុងបណ្តឹងសាទុក្ខនេះ នឹងត្រូវអង្គជំនុំជម្រះ

---

[9] *សូមមើល* កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ, មាត្រា ១៤(៧) ("គ្មានជនណាម្នាក់ ត្រូវយកមកចោទប្រកាន់ ឬយកមកផ្តន្ទាទោសសារជាថ្មីឡើយ ចំពោះបទល្មើសដែលបានផ្តន្ទាទោសជាស្ថាពរ ឬបានលើកលែងទោសស្របតាមច្បាប់ និងនីតិវិធីព្រហ្មទណ្ឌរបស់រដ្ឋនីមួយៗរួចហើយ (ដោយមានបន្ថែមការសង្កត់ន័យ)។

[10] សំណុំរឿង Green *ទល់នឹង សហរដ្ឋអាមេរិក*, 355 U.S. 184, 187-88 (ឆ្នាំ ១៩៥៧)។

[11] *សូមមើលឧទាហរណ៍* ដីកាដំណោះស្រាយ, ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០, ឯកសារ D427, កថាខណ្ឌ ១៦២២-១៦២៤; សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងការសម្រេចបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន នៅក្នុងដីកាដំណោះស្រាយ ឯកសារ D427/5/10, ថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១១។

[12] ប្រតិចារឹក, (ភាសាអង់គ្លេស), ថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១១, ឯកសារ E1/13.1, ទំព័រ ៣៦-៣៧, ប្រតិចារឹក (ភាសាអង់គ្លេស), ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១១, ឯកសារ E1/14.1, ទំព័រ ៨។

ដោះស្រាយ ហើយប្រសិនបើបណ្ដឹងសាទុក្ខនេះត្រូវបានដោះស្រាយជាបន្ទាន់ដំណាលគ្នានឹងពេលដែលសវនាការដែលកំពុងប្រព្រឹត្តទៅ នឹងកាត់បន្ថយភាពវែងអន្លាយ និងភាពស្មុគស្មាញនៃកិច្ចដំណើរការនីតិវិធីលើសាលដីកានៃបណ្ដឹងសាទុក្ខនេះ។ ដូចដែលយើងបានកត់សម្គាល់រួចមកហើយថា យើងអាចសន្សំសំចៃបានកាន់តែច្រើន ប្រសិនបើអង្គជំនុំជម្រះនេះបដិសេធជាស្ថាពរលើសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើអង្គសេចក្ដី។

៦. យើងបានយល់ឃើញថា បណ្ដឹងសាទុក្ខនេះមានលក្ខណៈអាចឲ្យទទួលយកបាន ដោយអនុលោមតាមមាត្រា ៣៣ ថ្មីនៃច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក ហើយយើងបានចេញសេចក្ដីសម្រេចមួយលើអង្គសេចក្ដី។ ប៉ុន្ដែដោយហេតុថា បញ្ហាទាំងប៉ុន្មានមានលក្ខណៈបើកទូលាយ សម្រាប់អង្គជំនុំជម្រះទាំងមូលធ្វើការពិនិត្យពិចារណាក្នុងលក្ខណៈជាផ្នែកមួយនៃសាលដីកាលើបណ្ដឹងសាទុក្ខ បន្ទាប់ពីបានស្ដាប់យោបល់ភាគី ទើបយើងយល់ឃើញថា យោបល់របស់យើងស្ដីពីអង្គសេចក្ដីនៃបណ្ដឹងសាទុក្ខនេះ ពុំទាន់មានសុពលភាពគតិយុត្តនៅដំណាក់កាលនេះទេ។